# លក្ខខណ្ឌទូទៅនៃការជាវ
# ប័ណ្ណសមាជិក និងសំបុត្រចូលរួមសកម្មភាពផ្សេងៗនៅបណ្ណាល័យពហុឯកសារ
# នៃវិទ្យាស្ថានបារាំងនៅកម្ពុជា

## ១. គោលបំណង

លក្ខខណ្ឌទូទៅត្រូវបានអនុវត្តចំពោះការជាវប័ណ្ណ ឬសំបុត្រដែលទាក់ទិននឹងរាល់សេវាកម្មទាំងឡាយដែលប្រព្រឹត្តទៅនៅក្នុងបណ្ណាល័យពហុឯកសារនៃវិទ្យាស្ថានបារាំងនៅកម្ពុជា។

សកម្មភាពនៅបណ្ណាល័យពហុឯកសារត្រូវបានរួមបញ្ចូលទាំងសេវាកម្មផ្សេងទៀតដែលមាននៅក្នុងវិទ្យាស្ថានបារាំងនៅកម្ពុជា។

ការប្រើប្រាស់សម្ភារៈ ឬសេវាកម្មក្នុងបណ្ណាល័យពហុឯកសារនៃវិទ្យាស្ថានបារាំងនៅកម្ពុជា គឺមានន័យថាអ្នកប្រើប្រាស់បានអាន និងយល់អំពីខ្លឹមសារនៃលក្ខណ្ឌទូទៅដែលមានចែងនេះ។

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះមានវិសាលភាពលើលក្ខណ្ឌទូទៅដទៃទៀត ឬជាក់លាក់ណាមួយដែលមិនបានចែងដោយវិទ្យាស្ថានបារាំងនៅកម្ពុជា។

វិទ្យាស្ថានបារាំងនៅកម្ពុជារក្សាសិទ្ធិក្នុងការកែប្រែលក្ខណ្ឌទូទៅគ្រប់ពេលវេលា។ ហេតុដូចនេះ អ្នកប្រើប្រាស់សេវាកម្មតម្រូវឲ្យចុះហត្ថលេខា ឬយល់ព្រមចំពោះលក្ខណ្ឌទូទៅរាល់ពេលដែលពួកគេចុះឈ្មោះសារជាថ្មី។

## ២. តម្លៃ

- តម្លៃប័ណ្ណសមាជិក និងសំបុត្រត្រូវបានកំណត់ជាប្រាក់ដុល្លារអាមេរិកដោយគិតរួមបញ្ចូលពន្ធជាស្រេច (TTC)។
- វិទ្យាស្ថានបារាំងរក្សាសិទ្ធិក្នុងការកែប្រែតម្លៃគ្រប់ពេលវេលា ប៉ុន្តែតម្លៃប័ណ្ណសមាជិក និងសំបុត្រចូលរួមសកម្មភាពកំសាន្តត្រូវបានកំណត់ដោយផ្អែកលើតារាងតម្លៃដែលបានអនុម័តជាធរមាននៅពេលបញ្ជាទិញ។

## ៣. របៀបនៃការបង់ប្រាក់

មធ្យោបាយទូទាត់ប្រាក់ដែលអនុញ្ញាតរួមមាន៖

- សម្រាប់ការទូទាត់ដោយផ្ទាល់នៅបញ្ជរផ្តល់ព័ត៌មាន ៖ ដោយកាតធនាគារ ស្កេនQR និងសាច់ប្រាក់។
- សម្រាប់ការទូទាត់នៅកន្លែងទទួលភ្ញៀវរបស់បណ្ណាល័យពហុឯកសារ ៖តាមរយៈការស្កេន QRកូដតែមួយមុខគត់ប្រសិនបើគ្មានបុគ្គលិកប្រចាំការនៅបញ្ជរផ្តល់ព័ត៌មានវិទ្យាស្ថាន។

ការបង់ប្រាក់ត្រូវធ្វើឡើងតែម្តង និងទាំងអស់បន្ទាប់ពីបានធ្វើការចុះឈ្មោះដោយជោគជ័យ។

## ៤. ដំណើរការនៃការចុះឈ្មោះ

<u>**ការចុះឈ្មោះនៅកន្លែងទទួលភ្ញៀវបណ្ណាល័យពហុឯកសារនៃវិទ្យាស្ថានបារាំងនៅកម្ពុជា៖**</u>

ការជាវនិងការបន្តប័ណ្ណសមាជិកបណ្ណាល័យពហុឯកសារត្រូវធ្វើនៅកន្លែងទទួលភ្ញៀវរបស់បណ្ណាល័យពហុឯកសារនៃវិទ្យាស្ថាន។

សម្រាប់ការធ្វើប័ណ្ណសមាជិក តម្រូវឲ្យអ្នកប្រើប្រាស់បំពេញទម្រង់បែបបទដោយចុះហត្ថលេខា និងថ្ងៃខែរួចបង្ហាញឯកសារយោងផ្សេងៗដើម្បីទទួលបានការបញ្ចុះតម្លៃ ឬដោយឥតគិតថ្លៃចំពោះសិស្សនិស្សិតដែលមានប័ណ្ណសម្គាល់រៀនភាសាបារាំងដែលមានសុពលភាព ឬចុងបង្កាន់ដៃចុះឈ្មោះរៀននៅមជ្ឈមណ្ឌលភាសា (សូមមើលមាត្រា៨)។

សម្រាប់អ្នកដែលមិនទទួលបានការផ្តល់សេវាឥតគិតថ្លៃ ត្រូវទៅទីតាំងផ្តល់ព័ត៌មានរបស់វិទ្យាស្ថានដោយបង្ហាញទម្រង់ចុះឈ្មោះដែលបានបំពេញរួចដើម្បីធ្វើការទូទាត់ប្រាក់ ។ បន្ទាប់ពីបង់ប្រាក់រួចត្រូវយកបង្កាន់ដៃទៅបង្ហាញកន្លែងទទួលភ្ញៀវក្នុងបណ្ណាល័យដើម្បីចុះឈ្មោះក្នុងប្រព័ន្ធ រួចបណ្ណារក្សនឹងធ្វើការបោះពុម្ពប័ណ្ណសមាជិកជូនអ្នកប្រើប្រាស់។

**ការចុះឈ្មោះចូលរួមសកម្មភាពនៅបញ្ជរផ្តល់ព័ត៌មានរបស់វិទ្យាស្ថានបារាំងនៅកម្ពុជា៖**

1) **ការចុះឈ្មោះនៅបញ្ជរផ្តល់ព័ត៌មាន**

ការចុះឈ្មោះចូលរួមសកម្មភាពផ្សេងៗ និងការបង់ប្រាក់អាចធ្វើឡើងដោយផ្ទាល់នៅបញ្ជរផ្តល់ព័ត៌មានរបស់វិទ្យាស្ថាន។

ការចុះឈ្មោះនឹងបន្តទទួលរហូតដល់អស់កន្លែងទំនេរ។ តម្លៃអាចប្រែប្រួលទៅតាមប្រភេទនៃសកម្មភាពនីមួយៗ (មើលមាត្រា ៨) ។

បន្ទាប់ពីបង់ប្រាក់រួចភ្នាក់ងារផ្តល់ព័ត៌មាននឹងផ្តល់បង្កាន់បង់ប្រាក់ រួមទាំងបោះត្រាសម្គាល់នៅលើដៃរបស់អ្នកចូលរួមដើម្បីឲ្យក្រុមការងារបណ្ណាល័យធ្វើការត្រួតពិនិត្យ និងអនុញ្ញាតឲ្យចូលរួមក្នុងសកម្មភាពនោះ។

2) **ការចុះឈ្មោះតាមរយៈគេហទំព័ររបស់វិទ្យាស្ថាន**

ការចុះឈ្មោះចូលរួមសកម្មភាពក៏អាចធ្វើឡើងតាមរយៈគេហទំព័ររបស់វិទ្យាស្ថានផងដែរ។

ការចុះឈ្មោះនឹងបន្តទទួលរហូតដល់អស់កន្លែងទំនេរ។ តម្លៃអាចប្រែប្រួលទៅតាមប្រភេទនៃសកម្មភាពនីមួយៗ (មើលមាត្រា ៨) ។

អ្នកចូលរួមត្រូវបង្ហាញ QRកូដ ទៅកាន់ភ្នាក់ងារផ្តល់ព័ត៌មានដើម្បីទទួលបានត្រាសម្គាល់នៅលើដៃ ដើម្បីឲ្យក្រុមការងារបណ្ណាល័យធ្វើការត្រួតពិនិត្យ និងអនុញ្ញាតឲ្យចូលរួមក្នុងសកម្មភាពនោះ។

## ៥. សិទ្ធិខ្ចីឯកសារ និងការចូលរួមសកម្មភាពរបស់បណ្ណាល័យ

- ខ្ចីឯកសារចំនួន១២ក្បាល មានសុពលភាព ៣សប្តាហ៍ (ក្នុងនោះមាន DVD ចំនួន៥ ច្រើនបំផុត)
- ខ្ចីឯកសារចំនួន ៤០ក្បាល មានសុពលភាព ៣សប្តាហ៍ (ក្នុងនោះមាន DVD ចំនួន៥ ច្រើនបំផុត) សម្រាប់ប័ណ្ណសមាជិកគ្រួសារ)

- ការខ្ចីបន្តអាចធ្វើបាន១ដង (ក្នុងករណីឯកសារនោះពុំមានត្រូវបានកក់ទុកមុន)
- ប័ណ្ណសមាជិកផ្តល់អត្ថប្រយោជន៍បន្ថែមសម្រាប់ការចូលទៅប្រើប្រាស់សេវា Culturethèque ដែលជាបណ្ណាល័យឌីជីថលភាសាបារាំង រួមទាំងកម្មវិធី Ludothèque។
- ធនធានឯកសារដែលមាននៅបណ្ណាល័យអាចអនុញ្ញាតខ្ចីយកទៅផ្ទះបាន លើកលែងតែប្រភេទវចនានុក្រម និង Encyclopédie។
- ក្នុងករណីដែលការសងឯកសារមានការយឺតយ៉ាវ មិនមានការពិន័យជាប្រាក់នោះទេ ប៉ុន្តែសមាជិកមិនអាចខ្ចីឯកសារបន្តទៀតបានទេ ដរាបណាឯកសារដែលបានខ្ចីមិនទាន់ត្រូវបានត្រឡប់យកមកសងវិញ។
- ក្នុងករណីមានការខូចខាត ឬហែកដោយកត្តាណាមួយ បណ្ណារក្សនឹងពិនិត្យវិនិច្ឆ័យតាមជាក់ស្តែង។ ប្រសិនបើរកឃើញថាឯកសារនោះមិនអាចប្រើប្រាស់បន្តទៀតបានទេ សមាជិកប័ណ្ណតម្រូវឲ្យប្តូរថ្មី ឬប្រសិនបើឯកសារនោះមិនទាន់បោះពុម្ពបណ្ណារក្ស និងសមាជិកប័ណ្ណព្រមព្រៀងទិញសៀវភៅថ្មីដែលមានតម្លៃស្មើ និងខ្លឹមសារប្រហាក់ប្រហែល។
- ក្នុងករណីមានការខូចខាតលើប្រភេទល្បែង ត្រូវផ្តល់ព័ត៌មានដល់បណ្ណារក្សដើម្បីពិនិត្យរកវិធីជួសជុល។ ក្នុងករណីមិនអាចជួសជុលបាន មានន័យថាល្បែងនោះនឹងលែងប្រើប្រាស់កើត ជាហេតុតម្រូវឲ្យសមាជិកប័ណ្ណត្រូវធ្វើការសង។ ក្នុងករណីមានសេចក្តីសម្រេចឲ្យសងល្បែងថ្មី ប្រសិនបើល្បែងនោះមិនមានផលិតឡើងវិញទេ បណ្ណារក្ស និងសមាជិកប័ណ្ណព្រមព្រៀងទិញល្បែងផ្សេងដែលមានភិនភាគ និងតម្លៃប្រហាក់ប្រហែល។ បញ្ជាក់៖ ករណីមានការជ្រុះបាត់ផ្នែកណាមួយនៃល្បែង សមាជិកប័ណ្ណមិនត្រូវរកបំណែកផ្សេងមកជំនួសដោយឯកឯង ដោយមិនបានជូនដំណឹងមកបណ្ណារក្សជាមុននោះទេ។
- វិទ្យាស្ថានបារាំងរក្សាសិទ្ធិក្នុងការបដិសេធមិនឲ្យចូលរួម ចំពោះសមាជិកណាដែលមិនគោរពលក្ខខណ្ឌអាយុសម្រាប់សកម្មភាពដែលរៀបចំដោយបណ្ណាល័យ ឧទាហរណ៍៖សកម្មភាពដែលមានប្រើប្រាស់សារធាតុគីមី -ល-។

## ៦. ការប្តូរសំបុត្រ និងការបង្វិលសងប្រាក់វិញ

- ប័ណ្ណសមាជិកបណ្ណាល័យ និងការចុះឈ្មោះចូលរួមសកម្មភាពដែលទិញរួចមិនអាចប្តូរវិញបានទេ។
- ក្នុងករណីសមាជិកដែលចូលរួមសកម្មភាពមិនស្របទៅនឹងលក្ខខណ្ឌជាមួយកម្មវិធី នឹងមានការប្តូរឲ្យទៅចូលរួមក្នុងកម្មវិធីផ្សេង។

## ៧. ការលុបចោល ឬការកែប្រែកម្មវិធី

- វិទ្យាស្ថានបារាំងរក្សាសិទ្ធិក្នុងការកែប្រែ ឬលុបចោលសកម្មភាពណាមួយក្នុងករណីមានឧបទ្ទវហេតុ ឬប្រធានសក្តិ (បញ្ហាបច្ចេកទេស លក្ខខណ្ឌអាកាសធាតុមិនអំណោយផល-ល-)។
- ក្នុងករណីកម្មវិធីណាមួយត្រូវបានលុបចោល បណ្ណាល័យនឹងរកដំណោះស្រាយក្នុងការប្តូរទៅកម្មវិធីមួយផ្សេងទៀត ។

## ៨. បញ្ជីតម្លៃ ការបញ្ចុះតម្លៃ និងការលើកលែងការបង់ប្រាក់សម្រាប់ប័ណ្ណសមាជិក

- ការបញ្ចុះតម្លៃត្រូវបានផ្តល់ជូនសមាជិកដែលបំពេញតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖
  - សិស្សនិស្សិតជនជាតិខ្មែរ និងក្មេងក្រោមអាយុ១៨ឆ្នាំ ដោយភ្ជាប់ជាមួយប័ណ្ណសិក្សា៖ **២ដុល្លារ**
  - សិស្សនិស្សិតបរទេស និងក្មេងក្រោមអាយុ១៨ឆ្នាំ ដោយភ្ជាប់ជាមួយប័ណ្ណសិក្សា៖ **៥ដុល្លារ**
  - មនុស្សវ័យជំទង់ជនជាតិខ្មែរ ដោយភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនដែលមានសុពលភាព ៖ **១៥ដុល្លារ**
  - មនុស្សវ័យជំទង់ជនជាតិបរទេស ដោយភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនដែលមានសុពលភាព ៖ **៣០ដុល្លារ**
  - បណ្ណសមាជិកគ្រួសារ ដោយភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនដែលមានសុពលភាព ៖ **៤០ដុល្លារ**
  - បណ្ណសមាជិកជាក្រុមសម្រាប់១០នាក់ មកពីស្ថាប័នតែមួយ ដោយភ្ជាប់មកជាមួយប័ណ្ណសម្គាល់បុគ្គលិក ៖ **៤០ដុល្លារ**
- ការលែកលែងការបង់ប្រាក់នឹងផ្តល់ជូនសម្រាប់
  - សិស្សដែលកំពុងរៀននៅមជ្ឈមណ្ឌលភាសា។ ប្រសិនបើពាក្យសុំធ្វើប័ណ្ណសមាជិកត្រូវបានដាក់ស្នើសុំមុន ប៉ុន្តែវគ្គសិក្សាត្រូវបានបញ្ចប់ រីឯសិស្សមិនបានចុះឈ្មោះរៀនបន្ត នោះការលើកលែងបង់ប្រាក់ប័ណ្ណសមាជិកមិនត្រូវបានអនុវត្តឡើយ។
  - បុគ្គលិករបស់វិទ្យាស្ថានបារាំងនៅកម្ពុជា។
- តម្លៃសកម្មភាពកំសាន្តមានការប្រែប្រួលទៅតាមប្រភេទនៃកម្មវិធី និងរយៈពេល
  - សកម្មភាពធម្មតា ចន្លោះពី៤៥នាទី ដល់៦០នាទី ៖ **៣ដុល្លារ**
  - សកម្មភាពជាក់លាក់ណាមួយ ដោយភ្ជាប់ជាមួយការបញ្ចាំងកុន ៖ **៥ដុល្លារ**
  - សកម្មភាពដែលមានរយៈពេល ៩០នាទី ៖ **៦ដុល្លារ**
  - សកម្មភាពជាក់លាក់ណាមួយដែលមានរយៈពេល ២ម៉ោង ៖ **១០ដុល្លារ**

## ៩. ការការពារទិន្នន័យផ្ទាល់ខ្លួន

- ព័ត៌មានពាក់ព័ន្ធនឹងអតិថិជនដែលប្រមូលបានក្នុងអំឡុងពេលជាវប័ណ្ណសមាជិក ឬសំបុត្រចូលរួមគឺមានភាពចាំបាច់សម្រាប់ការគ្រប់គ្រងប្រតិបត្តិការ និងដើម្បីគោរពតាមកាតព្វកិច្ចផ្លូវច្បាប់។
- យោងតាមច្បាប់ព័ត៌មានវិទ្យា និងសិទ្ធិសេរីភាពក្នុងការការពារទិន្នន័យ អតិថិជនមានសិទ្ធិចូលប្រើ កែតម្រូវ និងលុបទិន្នន័យផ្ទាល់ខ្លួនបាន ។

## ១០. ទំនួលខុសត្រូវ

- វិទ្យាស្ថានបារាំងមិនទទួលខុសត្រូវក្នុងករណីបាត់បង់ អំពើចោរកម្មក្នុងបរិវេណរបស់វិទ្យាស្ថាន។

- វិទ្យាស្ថានមិនទទួលខុសត្រូវចំពោះការខូចខាតឬគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់សម្ភារៈកំឡុងពេលចូលរួមសកម្មភាព។

## ១១. សិទ្ធិចូលទស្សនា និងសន្តិសុខសុវត្ថិភាព

សមាជិកត្រូវគោរពតាមបទបញ្ជាសុវត្ថិភាពជាធរមានរបស់វិទ្យាស្ថាន។ ការបង្កឲ្យមានបាតុភាព ឬការមិនគោរពតាមបទបញ្ជាអាចនាំឲ្យមានមានការបណ្តេញចេញពីរោងកុន ឬកម្មវិធីព្រឹត្តិការណ៍ដោយមិនមានការសងប្រាក់វិញឡើយ។

## ១២. បណ្តឹង

ចំពោះការតវ៉ាណាមួយទាក់ទងនឹងបណ្ណាល័យ សូមសមាជិកទាក់ទងមកកាន់វិទ្យាស្ថានបារាំងនៅកម្ពុជាតាមរយៈអ៊ីមែលខាងក្រោម៖

- mediatheque@ifcambodge.com

## ១៣. វិវាទ

ក្នុងករណីមានវិវាទ ត្រូវចូលរួមសហការដោះស្រាយដោយសន្តិវិធី។ ក្នុងករណីមិនសះ វិវាទនឹងស្ថិតក្រោមយុត្តាធិការផ្តាច់មុខរបស់តុលាការរាជធានីភ្នំពេញ។

## ១៤. ដែនអនុវត្តច្បាប់

- លក្ខខណ្ឌទូទៅទាំងអស់ត្រូវបានកំណត់ដោយច្បាប់នៃប្រទេសកម្ពុជា។

**ឈ្មោះអ្នកប្រើប្រាស់/អាណាព្យាបាលស្របច្បាប់ និងហត្ថលេខា**

------------------------------------------------------------------------